**ធនាគារជាតិ នៃ កម្ពុជា**

លេខ: ៨១៣.៧២.០១៤ ប្រកាសព័ត៌មាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃពុធ ៣រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន
## សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៨ ឆ្នាំ២០២១
## ស្តីពី "បញ្ហាប្រឈម និងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា"

៙៙៙៚៚៚

ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៨ ឆ្នាំ២០២១ ស្តីពី "បញ្ហាប្រឈម និងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា" ក្រោមអធិបតីភាពរបស់លោកជំទាវបណ្ឌិត ជា សិរី ឧបការីទេសាភិបាលនិងជាអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជា និងលោកស្រី Alissar Chaker តំណាងយូអិនឌីភីប្រចាំកម្ពុជា (UNDP Cambodia)។ សន្និសីទនេះ មានគោលបំណងលើកកម្ពស់ការស្រាវជ្រាវនិងកិច្ចពិភាក្សាដើម្បីរួមចំណែកផ្តល់ធាតុចូលក្នុងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។

សន្និសីទនេះមានការអញ្ជើញចូលរួមដោយផ្ទាល់ពីតំណាងមកពីក្រសួង-ស្ថាប័ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និងសាកលវិទ្យាល័យ ព្រមទាំងការចូលរួមតាមប្រព័ន្ធអនឡាញនៅលើគេហទំព័រហ្វេសប៊ុករបស់ធនាគារជាតិនៃកម្ពុជា។ អង្គសន្និសីទបានវាយតម្លៃខ្ពស់ចំពោះតួនាទីរបស់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា ដែលបច្ចុប្បន្នមានប្រមាណជាង ៩០% និងបានរួមចំណែកជិត ៦០% នៃផលិតផលក្នុងស្រុកសរុប និងបង្កើតការងារជាង ៧០% នៃកម្លាំងពលកម្ម។ នៅក្នុងវិបត្តិជំងឺកូវីដ-១៩ សហគ្រាសធុនតូចនិងមធ្យមបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំង បន្ថែមលើបញ្ហាប្រឈមដែលមានស្រាប់។

ជារួម លទ្ធផលនៃការស្រាវជ្រាវដែលមាននៅក្នុងសន្និសីទនេះបានបង្ហាញថា៖

- សហគ្រាសធុនតូចនិងមធ្យម (SMEs) ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈការលើកកម្ពស់អត្រាមានការងារធ្វើ ជាពិសេសសម្រាប់ស្ត្រី និងកាត់បន្ថយភាពក្រីក្រ។
- សហគ្រាសនិងអង្គភាពធុរកិច្ចទាំងអស់បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ ទៅលើតម្រូវការលើផលិតផល និងប្រាក់ចំណេញ ប៉ុន្តែសហគ្រាសធុនមីក្រូ តូច និងមធ្យមផ្លូវការគឺមានភាពធន់នឹងវិបត្តិច្រើនជាង ដោយមិនបានប្រើយុទ្ធសាស្ត្រដោះស្រាយបែបអវិជ្ជមានដូចជា លក់ទ្រព្យសកម្ម ឬខ្ចីបន្ថែមនោះទេ។
- តម្រូវការនិងការផ្គត់ផ្គង់ឥណទានសម្រាប់ SMEs មានកំណើនយឺតក្នុងអំឡុងពេលវិបត្តិ ប៉ុន្តែគុណភាពឥណទាននៅតែមានភាពល្អប្រសើរ ដែលមួយផ្នែកបណ្តាលមកពីការរៀបចំឥណទានឡើងវិញ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- SMEs ភាគច្រើនបន្តស្ថិតក្នុងវិស័យក្រៅប្រព័ន្ធ ដោយ SMEs ទាំងនោះយល់ថា នីតិវិធីចុះបញ្ជីមានភាពស្មុគស្មាញ ចំណាយពេលវេលាយូរ និងកម្រៃសេវាច្រើន ហើយមិនសូវយល់ដឹងពីអត្ថប្រយោជន៍ដែលអាចទទួលបានពីការចុះបញ្ជីផ្លូវការ។
- SMEs នៅកម្ពុជាបានជួបប្រទះនឹងបញ្ហាប្រឈម ដូចជា ការខ្វះដើមទុន របៀបនៃការគ្រប់គ្រងបែបប្រពៃណី ការខ្វះបុគ្គលិកដែលមានជំនាញច្បាស់លាស់ និងលទ្ធភាពទទួលបានព័ត៌មានទីផ្សារ ឥណទាន និងបច្ចេកវិទ្យានៅមានកម្រិត។
- លើសពីនេះ វិបត្តិជំងឺកូវីដ-១៩ បានបង្កឱ្យមានបញ្ហាប្រឈមផ្សេងទៀតដូចជា ការធ្លាក់ចុះយ៉ាងគំហុកនៃប្រាក់ចំណូល សន្ទនីយភាពឬសាច់ប្រាក់មានកម្រិត បញ្ហាសុខភាពផ្លូវចិត្តរបស់ម្ចាស់សហគ្រាស និងបញ្ហាខ្សែច្រវាក់ផ្គត់ផ្គង់។ ទោះយ៉ាងណា វិបត្តិសុខភាពនេះបានលើកទឹកចិត្តឱ្យ SMEs ងាកទៅរកការវិនិយោគលើបច្ចេកវិទ្យាឌីជីថល និងអភិវឌ្ឍសមត្ថភាពបុគ្គលិក ដើម្បីឱ្យស្របតាមការប្រែប្រួលនៃបច្ចេកវិទ្យា។

កិច្ចពិភាក្សាក៏បានលើកឡើងបន្ថែមផងដែរពីបញ្ហាប្រឈមសំខាន់ៗ ដែល SMEs បាននិងកំពុងជួបប្រទះ មានដូចជា SMEs ភាគច្រើនមិនបានធ្វើការចុះបញ្ជីដែលធ្វើឱ្យពួកគេពិបាកនៅក្នុងការស្វែងរកជំនួយហិរញ្ញវត្ថុពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុក្នុងពេលមានវិបត្តិ ការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តិផ្សេងនៅមានកម្រិត តម្លៃភស្តុភាកម្មនៅមានកម្រិតខ្ពស់ជាងបណ្តាប្រទេសប្រកួតប្រជែង ការបត់បែនតាមបរិបទនៃការវិវត្តរបស់សេដ្ឋកិច្ចក្នុងតំបន់និងពិភពលោកនៅមានកម្រិត មិនមានការប្រើប្រាស់បច្ចេកវិទ្យាទូលំទូលាយពិសេសក្នុងបរិបទសេដ្ឋកិច្ចឌីជីថល។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាច្រើនមានដូចជា ការលើកលែងពន្ធចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍និងបដិសណ្ឋារកិច្ចដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិកូវីដ-១៩ ការបង្កើត មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព មូលនិធិអភិវឌ្ឍន៍ជំនាញ កម្មវិធីសហហិរញ្ញប្បទានតាមរយៈធនាគារសហគ្រាសធុនតូចនិងមធ្យម សាជីវកម្មធានាឥណទានកម្ពុជា និងកម្មវិធីបណ្តុះបណ្តាលសហគ្រិនភាព ជាដើម។ លើសពីនេះ ដើម្បីទទួលបានហិរញ្ញប្បទាន និងជំនួយបច្ចេកទេសផ្សេងៗ រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យ SMEs ធ្វើការចុះបញ្ជីពាណិជ្ជកម្ម ដែលបច្ចុប្បន្នរាជរដ្ឋាភិបាលបានបង្កើតថ្នាលចុះបញ្ជីអនឡាញដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធជាច្រើន។

សន្និសីទនេះប្រព្រឹត្តទៅដោយជោគជ័យ ហើយលទ្ធផលនៃការស្រាវជ្រាវនឹងផ្សព្វផ្សាយនៅលើគេហទំព័រធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជា គ្រោងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៩ នៅឆ្នាំ២០២២ ខាងមុខ ដើម្បីបន្តលើកកម្ពស់ការស្រាវជ្រាវនិងកិច្ចពិភាក្សាលើប្រធានបទដែលមានសារៈសំខាន់ពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ច។ ៕

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA